# ព្រះរាជាណាចក្រកម្ពុជា

*ជាតិ សាសនា ព្រះមហាក្សត្រ*

## កិច្ចព្រមព្រៀង
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើឡើងរវាងរោងចក្រ **យីងហ្វេសិនហ្គាមេន ខូអិលធីឌី** ដែលមានលោក **លី យៀនហ៊ុយ** ជានាយករោងចក្រហៅកាត់ថាភាគី (ក) ។

**និង**

តំណាងប្រតិភូបុគ្គលិក និងសហជីពខ្មែរដើម្បីខ្មែរ នៃរោងចក្រ **យីងហ្វេសិនហ្គាមេន ខូអិលធីឌី** ហៅកាត់ថាភាគី (ខ) ។

**ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខណ្ឌដូចខាងក្រោម៖**

**ប្រការ១**

ភាគី (ក) នឹងរៀបចំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតផ្នែក គុកាត់ មូលហេតុខ្វះការបញ្ជាទិញ ដោយសាការរីករាលដាលនៃជម្ងឺកូវីត-១៩។ ការព្យួរកិច្ចសន្យាការងារនេះប្រព្រឹតទៅចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០។

**ប្រការ២**

ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ភាគី (ក) ផ្តល់ប្រាក់ឧបត្ថម្ភជូនដល់កម្មករនិយោជិតម្នាក់ៗចំនួន ៣០ (សាមសិប) ដុល្លាអាមេរិកក្នុងមួយខែ។

**ប្រការ៣**

ភាគី (ក) ត្រូវបើកប្រាក់ឧបត្ថម្ភព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិតនៅថ្ងៃទី០៧ ខែសីហា និងថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០។

**ប្រការ៤**

កម្មករនិយោជិតត្រូវបញ្ចប់ការព្យួរកិច្ចសន្យាការងារ និងចូលធ្វើការវិញនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០។ កម្មករនិយោជិតដែលមិនបានមកបំរើការងារវិញតាមកាលបរិច្ឆេតនេះចាត់ទុកអវត្តមានគ្មានច្បាប់។

**ប្រការ៥**

ភាគី (ក) និងភាគី (ខ) ឯកភាពយល់ព្រមអនុវត្តតាមប្រការនីមួយខាងចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពស ២៥៦៤

**រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០**

| | |
|---|---|
| **ភាគី (ក) តំណាង រោងចក្រ យីងហ្វេសិន** | **ភាគី (ខ) តំណាង សហជីពខ្មែរដើម្បីខ្មែរ-ប្រតិភូបុគ្គលិក** |

ហ្វេសិន ហ្គាមេន

YING FASHION GARMENT CO., LTD.

រាជធានីភ្នំពេញ